**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ:** ៥៧៣ ស.ជ.ណ

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១០

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ**

**គ្រប់ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល**

**កម្មវត្ថុ** : ស្តីពីតារាងចំណាយនៃចំណាយប្រតិបត្តិការអាទិភាពក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍ ។

**យោង** : ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើសំណើចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវមេត្តាជ្រាបថា សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានយល់ព្រមលើតារាងចំណាយនៃចំណាយប្រតិបត្តិការអាទិភាពក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍ ដែលមានខ្លឹមសារសំខាន់ៗដូចខាងក្រោម :

១- ការរៀបចំតារាងចំណាយផ្តោតលើគោលដៅ ៣ កម្រិត គឺ : កម្រិតទី១- ការចំណាយសម្រាប់ថ្នាក់ជាតិ ឬសេវាទ្រទ្រង់ កម្រិតទី២- ការចំណាយសម្រាប់ថ្នាក់ក្រោមជាតិ ឬសេវាជួរមុខ និងកម្រិតទី ៣- ការចំណាយសម្រាប់អ្នកឯកទេសកម្រិតខ្ពស់ ។

២- របៀបទូទាត់ការចំណាយផ្អែកលើគោលដៅ ៣ គឺ : ទី១- ការចំណាយប្រចាំថ្ងៃ ទី២- ការចំណាយលើការធ្វើទំនាក់ទំនង ទី៣-ការចំណាយលើការធ្វើដំណើរ ។ បូកសរុបលើចំណាយទាំង ៣ នេះ នឹងបានចំណាយសរុបប្រចាំខែសម្រាប់មុខងារនីមួយៗរបស់មន្ត្រីដែលបានចូលរួមអនុវត្តកម្មវិធី ឬគម្រោងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ ។ ការចំណាយនេះផ្អែកលើមុខងារនៅក្នុងកម្មវិធី

ឬគម្រោង ដែលខ្ពស់បំផុតមានចំនួនប្រមាណ ៤០០ ដុល្លារ សម្រាប់មុខងារដឹកនាំកម្មវិធី និងទាបបំផុតប្រមាណ ៥០ ដុល្លារ សម្រាប់មុខងារប្រតិបត្តិកម្រិតបឋម ។

៣- តារាងចំណាយនេះ ត្រូវអនុវត្តជាតារាងចំណាយស្តង់ដាររួមសម្រាប់គ្រប់ក្រសួង ស្ថាប័នដែលបានអនុវត្តកម្មវិធី ឬគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍ ហើយត្រូវបានពិនិត្យឡើងវិញជារៀងរាល់ ១៨ ខែម្តងយ៉ាងយូរ ។

៤- កម្រិតចំណាយប្រតិបត្តិការអាទិភាពប្រចាំខែ សម្រាប់ថ្នាក់ជាតិ ឬសេវាទ្រទ្រង់មាន :

- ចំណាយប្រតិបត្តិការការងារដឹកនាំកម្មវិធី ពី ៣៥០ ទៅ ៤០០ ដុល្លារ
  ( នាយកកម្មវិធី និង នាយករងកម្មវិធី )
- ចំណាយប្រតិបត្តិការការងារគ្រប់គ្រងគម្រោង ពី ២០០ ទៅ ៣០០ ដុល្លារ
  ( ប្រធានគម្រោង អនុប្រធានគម្រោង និង ប្រធានផ្នែក)
- ចំណាយប្រតិបត្តិការការងារប្រតិបត្តិ ពី ១២០ ទៅ ១៨០ដុល្លារ
  ( មន្ត្រីជំនាញ និង មន្ត្រីទ្រទ្រង់ )

៥- កម្រិតចំណាយប្រតិបត្តិការអាទិភាពប្រចាំខែ សម្រាប់ថ្នាក់ក្រោមជាតិ ឬសេវាជួរមុខ មាន :

- ចំណាយប្រតិបត្តិការការងារគ្រប់គ្រងគម្រោង ពី ៩០ ទៅ ១១០ ដុល្លារ
  (ប្រធានគម្រោង និង អនុប្រធានគម្រោង)
- ចំណាយប្រតិបត្តិការការងារប្រតិបត្តិ ពី ៥០ ទៅ ៧០ ដុល្លារ
  ( មន្ត្រីជំនាញ និង មន្ត្រីទ្រទ្រង់ )

តារាងចំណាយនៃគម្រោងចំណាយប្រតិបត្តិការអាទិភាពខាងលើនេះ នឹងត្រូវអនុវត្តនៅដើមខែ កក្កដា ឆ្នាំ ២០១០ ដោយមានការចរចា និងឯកភាពជាមួយដៃគូអភិវឌ្ឍតាមវិស័យនីមួយៗលើការអនុវត្តតារាងចំណាយ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវមេត្តាជ្រាប និងអនុវត្តតាមការគួរ ។

សូមឯកឧត្តម លោកជំទាវមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**ចម្លងជូន**

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ឯកសារ- កាលប្បវត្តិ